ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំង
អំពើជួញដូរមនុស្ស
**អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ**
លេខាធិការដ្ឋានរដ្ឋបាល-សរុប

# កំណត់ហេតុ

## កិច្ចប្រជុំពិភាក្សាពិនិត្យលើវិធានការបណ្តោះអាសន្ន ស្តីពី "ការពពោះជំនួស"

ថ្ងៃព្រហស្បតិ៍ បីរោច ខែបុស្ស ឆ្នាំរកា នព្វស័ក ព.ស ពីរពាន់ប្រាំរយហុកសិបមួយ ត្រូវនឹងថ្ងៃទីបួន ខែមករា ឆ្នាំពីរពាន់ដប់ប្រាំបី វេលាម៉ោងប្រាំបី និងសែសិបប្រាំនាទី នៅសាលប្រជុំអគ្គលេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស មានបើកកិច្ចប្រជុំពិភាក្សាពិនិត្យលើវិធានការបណ្តោះអាសន្ន ស្តីពី ការពពោះជំនួស ក្រោមអធិបតីភាព **លោកជំទាវ ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ ដោយមានការអញ្ជើញចូលរួមពី ឯកឧត្តម លោកជំទាវ លោក លោកស្រី តំណាងក្រសួង ស្ថាប័នពាក់ព័ន្ធ ដូចជា ក្រសួងកិច្ចការនារី ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួងសុខាភិបាល ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ក្រសួងយុត្តិធម៌ អគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម អគ្គនាយកដ្ឋានអន្តោប្រវេសន៍ អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន និងមន្ត្រីពាក់ព័ន្ធមួយចំនួនទៀត។

ជាកិច្ចចាប់ផ្តើម លោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ មានប្រសាសន៍ស្វាគមន៍ ចំពោះវត្តមាន ឯកឧត្តម លោកជំទាវ លោក លោកស្រី និងមន្ត្រីពាក់ព័ន្ធទាំងអស់ដែលបានអញ្ជើញចូលរួមនាពេលនេះ។ លោកជំទាវ បានមានប្រសាសន៍ថា កិច្ចប្រជុំនេះ គឺ ធ្វើឡើងតាមសំណើរបស់លោកជំទាវវេជ្ជបណ្ឌិត រដ្ឋមន្ត្រីក្រសួងកិច្ចការនារី ដោយគោរពស្នើសុំ សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.ប.ជ ដាក់ចេញនូវវិធានការបន្ទាន់លើករណីពពោះជំនួស ក្នុងចន្លោះពេលដែលពុំទាន់មានច្បាប់នៅឡើយ។ លោកជំទាវ មានប្រសាសន៍បន្តទៀតថា៖ ចំពោះករណីដែលបានកើតមានកន្លងមក គឺមានអ្នកមកស្នើសុំកូនករណីពពោះជំនួសនេះ ទៅដល់តុលាការរាជធានីភ្នំពេញ មានចំនួន ១២ករណីហើយ។ តើវិធានការសម្រាប់អនុវត្តបន្តក្នុងដំណាក់កាលមិនទាន់មានច្បាប់ត្រូវធ្វើយ៉ាងណា? រឹតបន្តឹង បន្ធូរបន្ថយ ឬបើកទូលាយ? សូមឲ្យអង្គប្រជុំលើកឡើងជាមតិយោបល់ ដើម្បីបង្ការទប់ស្កាត់ ព្រមទាំងវិធានការយ៉ាងសមស្រប សម្រាប់អនុវត្តរួមគ្នា ។

លោក **ណុប រដ្ឋា** អនុប្រធាននាយកដ្ឋាន នៃក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ យោងសេចក្តីជូនដំណឹងរបស់រាជរដ្ឋាភិបាលលេខ ២៥៣ សជណ ចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១៧ ស្តីពីគោលការណ៍ដោះស្រាយករណីទារកដែលកើតដោយ ការជួលស្ត្រីខ្មែរឲ្យពពោះជំនួស ដើម្បីយកទារកចេញទៅចិញ្ចឹមនៅក្រៅប្រទេស

នោះ ឱសានវាទត្រឹមថ្ងៃទី ០៨ ខែមករា ឆ្នាំ២០១៨ នេះហើយ ។ តាមប្រសាសន៍លោកជំទាវ មានចំនួន ១២ករណី បានធ្វើការស្នើសុំកូន(ទារក) ទៅតុលាការរួចហើយ ពាក់ព័ន្ធការជួលស្ត្រីខ្មែរឲ្យពពោះជំនួសនោះ។ ក្រៅពីនេះតើនៅមានប៉ុន្មានករណីទៀត? យើងគួរអនុវត្តបន្តតាមវិធានការដែលមានស្រាប់ ព្រោះកូន(ទារក) នោះជាកូនដែលកើតចេញពីម្តាយជាស្ត្រីខ្មែរ និងជានាសេចក្តីថ្លៃថ្នូររបស់ពលរដ្ឋយើង ជាពិសេសលើការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដើម្បីកុំឲ្យកម្ពុជាក្លាយជាគោលដៅ នៃការធ្វើអាជីវកម្មពពោះជំនួស ។

កញ្ញា **សែម សែងវវែថៃ** ប្រធាននាយកដ្ឋាន នៃក្រសួងយុត្តិធម៌ សេចក្តីព្រាងច្បាប់ស្តីពីការពពោះជំនួស ក្រសួងយុត្តិធម៌ កំពុងពិនិត្យ និងរៀបចំយ៉ាងយកចិត្តទុកដាក់បំផុតលើច្បាប់នេះ។ ដូចនេះ ករណីពពោះជំនួសនៅក្រោយឱសានវាទ ថ្ងៃទី០៨ ខែមករា ឆ្នាំ២០១៨ បើកើតមានថ្មី សូមឲ្យក្រសួងស្ថាប័នមានសមត្ថកិច្ចអនុវត្តតាមវិធានការដែលមានស្រាប់ ដោយផ្អែកលើអង្គហេតុនៃរឿង ហើយត្រូវដាក់បន្ទុកលើបទល្មើសនេះ ដោយយោងលើលិខិតលេខ ០២៤ អបស.មព ស្តីពីការមិនអនុញ្ញាតឲ្យធ្វើការផ្សាំ ឬ ជួញដូរកោសិកា ជាលិកា សរីរាង្គមនុស្ស កោសិកាមេជីវិត(ញី ឈ្មោល) ដោយគ្មានការអនុញ្ញាតពីក្រសួងសុខាភិបាល និងច្បាប់ស្តីពីការបង្រ្កាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ព្រមទាំងមាត្រាមួយចំនួនទៀត នៃក្រមព្រហ្មទណ្ឌ។ ដោយច្បាប់ពពោះជំនួសយើងពុំទាន់បានអនុម័ត និងដាក់ឲ្យប្រើប្រាស់ជាផ្លូវការនៅឡើយទេ។

**ឯកឧត្តម ឧត្តមសេនីយ៍ឯក ចៅង សំអាត** អគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ កិច្ចប្រជុំពាក់ព័ន្ធករណីជួលស្ត្រីខ្មែរឲ្យពពោះជំនួស គឺបានជួបប្រជុំពិភាក្សាគ្នា មិនតិចជាង១០លើកមកហើយទេ ហេតុចេញសជណ ២៥៣ ចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១៧ របស់ទីស្តីការគណៈរដ្ឋមន្ត្រី និងលិខិតលេខ ០៨៦/១៧ ចុះថ្ងៃទី ០២ ខែមិថុនា ឆ្នាំ២០១៧ របស់សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.ប.ជ។ ប៉ុន្តែករណីពពោះជំនួសនៅប្រទេសយើង ហាក់បីដូចពុំមានការស្ងប់ស្ងាត់សោះ មកទល់ពេលនេះ។ ក្រោយពីឱសានវាទត្រូវបានបញ្ចប់ ករណីនេះនៅតែបន្តកើតមាន គឺត្រូវរឹតបន្តឹងដើម្បីទប់ស្កាត់ការកើតឡើងនូវករណីថ្មី និងការពារមិនឲ្យកម្ពុជាក្លាយជាគោលដៅ នៃការធ្វើអាជីវកម្មជួញដូរទារកទៀតផង យើងត្រូវបង្កើនវិធានការរដ្ឋបាល ពិសេសការត្រួតពិនិត្យតាមគ្លីនិក មួយចំនួនដែលមានបច្ចេកវិទ្យា ពាក់ព័ន្ធនឹងការពពោះ និងត្រូវអនុវត្តតាមលិខិតលេខ០២៤ អបស.មព ដោយគ្មានការអនុញ្ញាតពីក្រសួងសុខាភិបាល និងច្បាប់ស្តីពីការបង្រ្កាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ព្រមទាំងមាត្រាមួយចំនួនទៀត នៃក្រមព្រហ្មទណ្ឌ ដែលយើងបានធ្វើរួចមកហើយ។ ឯកឧត្តម បានឯកភាពលើការលើកឡើងរបស់តំណាងក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ។

លោកជំទាវ **ច័ន្ទ ហាវ៉ានវឌ្ឍី** អនុរដ្ឋលេខាធិការក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា បានឯកភាពលើការលើកឡើងរបស់តំណាងក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ។ ប្រធានបទកិច្ចប្រជុំថ្ងៃនេះ មានចំនួន០២ គឺ៖

១.ពាក់ព័ន្ធជនបរទេសជាមួយស្ត្រីខ្មែរ ដែលជាអ្នកត្រូវគេជួលឲ្យពពោះជំនួស។

២.ពាក់ព័ន្ធពលរដ្ឋខ្មែរ(បុរស) ជាមួយស្ត្រីខ្មែរ ។

ដោយច្បាប់ពពោះជំនួសពុំទាន់ចេញឲ្យប្រើប្រាស់ជាផ្លូវការនៅឡើយ យើងគួរអនុវត្តតាមវិធានការ និងច្បាប់ដែលមានស្រាប់។ សូមគាំទ្រ ចំពោះការដាក់ទោសទណ្ឌលើអន្តរការីពាក់ព័ន្ធ ករណីជួលស្ត្រីខ្មែរឲ្យពពោះជំនួស បើករណីកើតមានជាថ្មីក្រោយពីឱសានវាទត្រូវបានបញ្ចប់ ។

**លោកជំទាវ ឌុច ដាណា អគ្គនាយករង** នៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម ចំពោះវិធានការរបស់យើងពិនិត្យមើលទៅ វាពុំមានការតឹងតែងនោះទេ មានតែការបន្ធូរបន្ថយច្រើន។ ដូច្នេះ ក្នុងដំណាក់កាលមិនទាន់មានច្បាប់ពពោះជំនួស គឺករណីនេះ ត្រូវតែបញ្ឈប់ កុំឲ្យកើតមានថ្មីទៀត ព្រោះអីនៅប្រទេសគេ ដូចជា ថៃ វៀតណាម... គេអនុវត្តបាន។

ប្រទេសកម្ពុជាយើង ជាប្រទេសនីតិរដ្ឋ ករណីជួលស្ត្រីខ្មែរឲ្យពពោះជំនួស វាជារឿងថ្មីសម្រាប់យើង ហើយវាប៉ះពាល់យ៉ាងធ្ងន់ធ្ងរ ដល់វប្បធម៌ប្រពៃណីជាតិខ្មែរ ព្រមទាំងធ្វើឲ្យប្រទេសយើងក្លាយជាទីផ្សារ ក្នុងការផលិតទារកថែមទៀត។ ដើម្បីកុំឲ្យកើតមានថ្មី យើងត្រូវតែរឹតបន្តឹង និងអនុវត្តឲ្យខានតែបាន ។

ប្រសាសន៍លោកជំទាវ **ជូ ប៊ុនអេង** ប្រធានអង្គប្រជុំ បានសរុបមតិយោបល់ ដែលបានលើកឡើងក្នុងអង្គប្រជុំនេះ ដោយបានធ្វើការឯកភាពគ្នា លើវិធានការដែលមានស្រាប់ ត្រូវអនុវត្តបន្តទៅតាមគោលការណ៍ សម្រាប់ស្ត្រីដែលមានគភ៌រួចមកហើយ។ ដូច្នេះ ក្នុងដំណាក់កាលច្បាប់មិនទាន់មាន ហើយករណីពពោះជំនួសនៅកើតមានជាថ្មី គឺយើងយកច្បាប់ដែលមានស្រាប់ដើម្បីអនុវត្តក្នុងការបង្ការ និងបង្ក្រាបកុំឲ្យកើតមានជាថ្មី ក្នុងនោះមានក្រសួង ស្ថាប័នចំនួន៣ មានតួនាទីដូចខាងក្រោមៈ

**១. តុលាការ** : អនុវត្តតាមនីតិវិធីតុលាការ

**២. ក្រសួងសុខាភិបាល** : យោងលិខិតលេខ០២៤ អបស.មព ស្តីពីការមិនអនុញ្ញាតឲ្យធ្វើការផ្សាំ ឬ ជួញដូរកោសិកា ជាលិកា សរីរាង្គមនុស្ស កោសិកាមេជីវិត(ញី ឈ្មោល) ដោយគ្មានការអនុញ្ញាតពីក្រសួងសុខាភិបាល និងលិខិតបទដ្ឋានពាក់ព័ន្ធមួយចំនួនទៀត។

**៣.ក្រសួងមហាផ្ទៃ** :

- ពង្រីកការផ្សព្វផ្សាយ អំពីសេចក្តីជូនដំណឹងរបស់រាជរដ្ឋាភិបាលលេខ២៥៣ សជណ ព្រមទាំងជូនដំណឹងទៅរដ្ឋបាលថ្នាក់ក្រោមជាតិ ដោយមានវិធានការណែនាំ អំពីនីតិវិធីក្នុងដំណាក់កាលបណ្តោះអាសន្ន ដែលចាំបាច់ត្រូវយកចិត្តទុកដាក់ ក្នុងការចេញសំបុត្រអត្រានុកូលដ្ឋាន ដល់ទារកដែលកើតដោយពលរដ្ឋខ្មែរ និងជនបរទេស ព្រមទាំងបទដ្ឋានពាក់ព័ន្ធផ្សេងៗ ដែលគេអាចយកទៅប្រើប្រាស់ ក្នុងគោលដៅខុសច្បាប់។

- ពង្រឹងការត្រួតពិនិត្យតាមបណ្តាច្រកទ្វារព្រំដែនទូទាំងប្រទេស ចំពោះករណីនាំទារកចេញដោយពិនិត្យឲ្យបានហ្មត់ចត់លើលិខិតបទដ្ឋានដែលបានប្រើប្រាស់ ជៀសវាងការផ្តល់ឱកាសឲ្យជនល្មើស ប្រើជាមធ្យោបាយនាំទារកចេញដោយខុសច្បាប់។

- បន្ត និង ពង្រឹងការតាមដានស៊ើបអង្កេត ករណីសង្ស័យពាក់ព័ន្ធនឹងការបំផុសឲ្យមាន ការពពោះជំនួស ឬល្បិចកលក្នុងការនាំទារកចេញ តាមមធ្យោបាយផ្សេងៗ ដែលគួរឲ្យសង្ស័យនៅតាមបណ្តាមូលដ្ឋាន បណ្តាច្រកទ្វារព្រំដែន ដើម្បីមានវិធានការតាមផ្លូវច្បាប់។

កិច្ចប្រជុំបានបញ្ចប់នៅវេលាម៉ោង ដប់ និងហាសិបប្រាំនាទី នាថ្ងៃ ខែ ឆ្នាំដដែល។

ថ្ងៃច័ន្ទ ០៧រោច ខែបុស្ស ឆ្នាំរកា ព.ស២៥៦១
រាជធានីភ្នំពេញ,ថ្ងៃទី ០៨ ខែមករា ឆ្នាំ២០១៨
អ្នកធ្វើកំណត់ហេតុ

វរសេនីយ៍ទោ ឌិក_សំឡៀង

**គោរពជូន**
**លោកជំទាវ អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ**
មេត្តាជ្រាបដ៏ខ្ពង់ខ្ពស់។
ថ្ងៃច័ន្ទ ០៧រោច ខែបុស្ស ឆ្នាំរកា នព្វស័ក ព.ស២៥៦១
រាជធានីភ្នំពេញ ថ្ងៃទី០៨ ខែមករា ឆ្នាំ២០១៨
ប្រធានលេខាធិការដ្ឋាន

**ឧត្តមសេនីយ៍ទោ. គង់_ពុទ្ធី**

ឯកភាព
11/01/18

ជួ_ប៊ុនអេង